ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣៤៤

ចុះថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ២០០១

សាលដីកា

លេខ : ១៥៧

ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០២

នាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ឌិត មុន្ទី ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២-លោក យស់ សូខេវ៉ឺន ចៅក្រមរបាយការណ៍

៣-លោក គង់ ភីរុន ចៅក្រម

៤-លោក ឈឹម ស៊ីផល ចៅក្រម

៥-លោក ប៉ែន សាវឿន ចៅក្រម

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញាស្តីទី

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ១៣៦ ចុះថ្ងៃទី ២៣.៨.២០០១ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ៤៥៨ ចុះថ្ងៃទី ១១.៧.២០០១ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ លី ធារី "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៣៨ឆ្នាំ ជាតិ ខ្មែរ របររកស៊ី មេផ្ទះ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ៣៦អាអឺ០អឺ១ ផ្លូវលេខ ២០៥ ក្រុមទី ២២ សង្កាត់ទួលស្វាយព្រៃទី២ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ម៉ុយ ម៉េង ម្តាយឈ្មោះ លី ឡេង ។

និង ចុងចម្លើយឈ្មោះ ឡៅ ស៊ីសុផល "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ របររកស៊ី យោធា ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៣៦អាអឺ០អឺ១ ផ្លូវលេខ ២០៥ សង្កាត់ទួលស្វាយព្រៃទី២ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ឡៅ ឆេងហ៊ាង "រ" ម្តាយឈ្មោះ នូ ពុំសែន "រ" ។ មានមេធាវីឈ្មោះ ចាន់ សុខឃាង ។

តតិយជន ឈ្មោះ ឡុង ស៊ុធី "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ របររកស៊ី អនុប្រធានផ្នែកច្បាប់ នៃ រដ្ឋសភា ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៩០អា ផ្លូវ ១៥០ សង្កាត់ផ្សារដេប៉ូ១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

ឪពុកឈ្មោះ ឡុង ផេត "វ" ម្តាយឈ្មោះ ម៉ន់ ម៉េងថៃ "ល" ។ ដែលមាន លោក ផាត់ ពៅសៀង ជាមេធាវី ។

កម្មវត្ថុបណ្តឹង : សុំផ្តាច់សមគ្គសង្វាស ពីប្តី

បានឃើញបណ្តឹងសាទុក្ខលេខ ៣៤៨ ចុះថ្ងៃទី ០៤.១០.២០០១ របស់លោក ឈិត ប៊ូរ៉ាវុធ ជាមេធាវីរបស់ឈ្មោះ ទៀវ ស៊ីសុផល និង បណ្តឹងសាទុក្ខលេខ ៣៧៥ ចុះថ្ងៃទី ២២.១០.២០០១ របស់ឈ្មោះ ទៀវ ស៊ីសុផល ប្តឹងមិនសុខចិត្តពីសាលដីកាលេខ១៣១ឈ ចុះថ្ងៃទី ២៣.៨.២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី ៣ និង ទី៥ នៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៤៤ ចុះថ្ងៃទី ០៤.១២.២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៥.៥.២០០០ របស់ដើមចោទឈ្មោះ លី ធារី ថា ខ្លួនប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តី ឈ្មោះ ទៀវ ស៊ីសុផល ដោយអាងហេតុថា កន្លងមករស់នៅពុំចុះសំរុងគ្នា ។ ខ្លួនបានរៀបការនៅឆ្នាំ ១៩៨៣ ខ្លួនសុំសិទ្ធិគ្រប់គ្រងផ្ទះលេខ ២៧អឺ០ ផ្លូវលេខ ៣១៨ សង្កាត់ទួលស្វាយព្រៃ២ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ឃ្លាំងមួយទំហំ ៧ម គុណ ២១ម ដែលស្ថិតនៅផ្លូវលេខ ៤៣០ សង្កាត់ទួលទំពូង ២ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ដីពីរកន្លែងទំហំ ៧,៥០ម គុណ ២៥ម និង ៩ម គុណ ២០ម នៅបូរី១០០ខ្នង សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ និង ផ្ទះ១នៅបារិត យកមកធ្វើជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។ ទ្រព្យសម្បត្តិនៅសល់ក្រៅពីនោះ ខ្លួនសុខចិត្តប្រគល់អោយទៅឈ្មោះ ទៀវ ស៊ីសុផល គ្រប់គ្រង រួមទាំងកូនស្រី ២នាក់ទៀតៗ

បានឃើញពាក្យបណ្តឹងសុំចូលជាតតិយជន ចុះថ្ងៃទី ០៤.០១.២០០១ របស់ឈ្មោះ ឡុង សុធី និង ប្រពន្ធឈ្មោះ លៀង សុនីតា ថា ខ្លួនសុំចូលជាតតិយជន ក្នុងសំណុំរឿង រដ្ឋប្បវេណីលេខ ៥៦៧ ចុះថ្ងៃទី ០៦.៧.២០០០ របស់តុលាការក្រុងភ្នំពេញ ទាមទារប្រាក់ពីឈ្មោះ លី ធារី និង ប្តីឈ្មោះ ទៀវ ស៊ីសុផល ចំនួន ៥៧.០០០ដុល្លាអាមេរិក ដែលអ្នកទាំងពីរពុំទាន់បានសងមកខ្លួននៅឡើយ ។

បានឃើញសាលក្រមលេខ ៤១ "ឈ" ចុះថ្ងៃទី ២២.៩.២០០០ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹង របស់ឈ្មោះ លី ធារី ចុះថ្ងៃទី ២៥.៥.២០០០ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បង្គាប់អោយឈ្មោះ លី ធារី និង ទៀវ ស៊ីសុផល ផ្តាច់សមគ្គសង្វាស

ពីគ្នា ចាប់ពីថ្ងៃនេះតទៅ ដោយអោយ លី ធារី ស្ថិតនៅភាពមេម៉ាយ រយៈពេល ៣០០ថ្ងៃ ចាប់ពីថ្ងៃនេះតទៅ តាមមាត្រានៃ ច្បាប់ អាពាហ៍ ពិពាហ៍ និង គ្រួសារ ។

៣-ប្រគល់ផ្ទះលេខ ២៧អឺ០ ផ្លូវ ៣១៨ សង្កាត់ទួលស្វាយព្រៃ២ ខ័ណ្ឌចំការមន ឃ្លាំងមួយទំហំ ១៧ គុណ ២១ នៅផ្លូវ ៤៣០ សង្កាត់ទួលទំពូង២ ខ័ណ្ឌចំការមន ដីពីរកន្លែងទំហំ ៧,៥០ គុណ ២៥ និង ៥ គុណ ២០ នៅបូរី១០០ខ្នង សង្កាត់ភ្នំពេញថ្មី និង ផ្ទះ ១ នៅបាទិត ប្រគល់ទៅអោយឈ្មោះ លី ធារី គ្រប់គ្រង និង ថែរក្សា ជាម្ចាស់កម្មសិទ្ធិ ចាប់ពីថ្ងៃនេះតទៅ ។

៤-ចំណែកឯកូនស្រីឈ្មោះ ទេព្រា សុវត្ថី ភេទស្រីអាយុ១៤ឆ្នាំ និង ឈ្មោះ ទេព្រា សុថាវិន ភេទស្រី អាយុ ១១ឆ្នាំ ព្រមទាំងប្រាក់តេដំពាក់ នៅសហរដ្ឋអាមេរិក ចំនួន ៧០.០០០ដុល្លា ប្រគល់អោយទៅឈ្មោះ ទេព្រា ស៊ីសុផល កាន់កាប់គ្រប់គ្រងចាប់ពីថ្ងៃនេះតទៅ ដោយអោយមាតាបីតា មានសិទ្ធិ សួរសុខទុក្ខ កូន និង ចិញ្ចឹមកូន តាមមាត្រា ៧៤ និង ៧៥ នៃច្បាប់អាពាហ៍ ពិពាហ៍ និង គ្រួសារ ។

៥-បង្គាប់អោយឈ្មោះ លី ធារី បង់ប្រាក់ប្រដាប់ក្តី រួមមាន ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីការកោះ ៥.០០០៛ សរុបទាំងអស់ ៧.០០០៛ ។

៦-សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខដើមចោទ និង កំបាំងមុខចុងចម្លើយ សំរេចបើកផ្លូវ បណ្តឹងទាស់ រយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃ ទទួលដំណឹងនេះតទៅ និង បើកផ្លូវបណ្តឹងឧទ្ធរណ៍ រយៈពេលពីរខែ គិតចាប់ពីថ្ងៃផុតកំណត់ បណ្តឹងទាស់ទៅ ។

បានឃើញបណ្តឹងទាស់ របស់ឈ្មោះ ទេព្រា ស៊ីសុផល ចុះថ្ងៃទី ១៩.១០.២០០០ ប្តឹងមិនសុខចិត្តត្រង់ចំនុចទី ៣ នៃសាលក្រមទាំងមូល ។

បានឃើញសាលក្រមលេខ ១៥ "ឃ" ចុះថ្ងៃទី ២៨.០២.២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ លើចំនុចទី៣ នៃសាលក្រមលេខ ៤១ "ឃ" ពីឈ្មោះ ទេព្រា ស៊ីសុផល ចុះថ្ងៃទី ១៩.១០.២០០០ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បដិសេធ ចំនុចទី៣ នៃសាលក្រមលេខ ៤១ "ឃ" ចុះថ្ងៃទី ២២.៩.២០០០ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ចាប់ពីពេលនេះតទៅ ។

៣-ទទួលពាក្យបណ្តឹង សុំចូលជាតតិយជន របស់ឈ្មោះ ឡុង សុធី ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៤-បង្គាប់អោយឈ្មោះ លី ធារី និង ឈ្មោះ ទេព្យា ស៊ីសុផល រួមគ្នាសងប្រាក់ដំពាក់ចំនួន ៥០.០០០ ដុល្លាអាមេរិក " ប្រាំម៉ឺនដុល្លាអាមេរិក " ការប្រាក់ចំនួន ៥ភាគរយ ក្នុង១ឆ្នាំ និង ជំងឺចិត្ត ចំនួន ៣.០០០ដុល្លាអាមេរិក " បីពាន់ដុល្លាអាមេរិក " ទៅអោយ ឈ្មោះ ឡុង សុធី បើឈ្មោះនេះគ្មានប្រាក់សង ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង សង សំណង តាមច្បាប់ បើឈ្មោះ លី ធារី និង ឈ្មោះ ទេព្យា ស៊ីសុផល រឹងរូស ត្រូវចាប់ដាក់គុក បង្ខំដល់រូបកាយតាមច្បាប់ តែមិនអោយលើស៨ខែ ។

៥-បង្គាប់អោយឈ្មោះ លី ធារី និង ឈ្មោះ ទេព្យា ស៊ីសុផល រួមគ្នាសង ប្រាក់ដំពាក់ ចំនួន ៣៧.០០០ ដុល្លាអាមេរិក " បីម៉ឺនប្រាំពីរពាន់ដុល្លាអាមេរិក " ទៅអោយ ឈ្មោះ ទេព្យា សុខារម្មណ៍ វិញ ។

៦-ប្រាក់ដែលគេដំពាក់ទាំងប៉ុន្មាន បង្គាប់អោយឈ្មោះ លី ធារី និង ឈ្មោះ ទេព្យា ស៊ីសុផល រួមគ្នាទារបាន ត្រូវបែងចែកជាពីរចំណែកស្មើគ្នា ។

៧-ទ្រព្យសម្បត្តិរួមទាំងប៉ុន្មាន របស់ឈ្មោះ លី ធារី និង ឈ្មោះ ទេព្យាស៊ីសុផល ដែលសល់ពីសងឈ្មោះ ឡុង សុធី និង ឈ្មោះ ទេព្យា សុខារម្មណ៍ ត្រូវបែងចែកជាពីរចំណែក ស្មើគ្នា ។

៨-បង្គាប់អោយឈ្មោះ ទេព្យា ស៊ីសុផល បង់ប្រាក់ប្រដាប់ក្តី រួមមាន ពន្ធចុះ បញ្ជីក្តី និង ពន្ធថ្លឹង ចំនួន ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ទីបប្រាក់ ២០០៛ រង្វាន់អ្នក ប្រគល់ដីកាកោះ ៥.០០០៛ សរុបទាំងអស់ ៧.០០០៛ ។

៩-សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខគូក្តី សំរេចបើកផ្លូវ បណ្តឹងឧទ្ធរណ៍ រយៈពេលពីរខែ គិតចាប់ពីថ្ងៃជំនុំជំរះនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ របស់ឈ្មោះ លី ធារី ចុះថ្ងៃទី ២៣.៤.២០០១ ប្តឹង មិនសុខចិត្តត្រង់ចំនុចទី៤ នៃសាលក្រមទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ទេព្យា ស៊ីសុផល ចុះថ្ងៃទី២៣.៤.២០០១ ប្តឹងមិនសុខចិត្ត ត្រង់ចំនុច ទី ៤ និង ទី៧ នៃសាលក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ១៣១ " ឃ " ចុះថ្ងៃទី ២៣.៨.២០០១ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៣.៤.២០០១ របស់ឈ្មោះ លី ធារី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយផ្អែក និង គតិច្បាប់ ។

២-ទទួលពាក្យ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៣.៤.២០០១ របស់ឈ្មោះ ទេព្យា ស៊ីសុផល ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយផ្អែកនិង គតិច្បាប់ ។

៣-តម្កល់សាលក្រម រដ្ឋប្បវេណីលេខ ១៥ "ឃ" ចុះថ្ងៃទី ២៨.០២.២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ប៉ុន្តែត្រូវកែប្រែ និង សរសេរ បញ្ជាក់ជាថ្មីថា ទ្រព្យសម្បត្តិរួមរវាងប្តីប្រពន្ធឈ្មោះ ទេព្យា ស៊ីសុផល និង ឈ្មោះ លី ធារី មាន ផ្ទះលេខ ២៧អ៊ី០ ផ្លូវ ៣១៨ សង្កាត់ទួលស្វាយព្រៃ២ ខ័ណ្ឌចំការមន ផ្ទៃក្រឡាទំហំ ១៧ម គុណ២១ម ស្ថិតនៅផ្លូវលេខ ៤៣០ ក្រុមទី ២៨ សង្កាត់ទួលទំពូង២ ខ័ណ្ឌចំការមន ដីនៅបូរី១១០០ខ្នង ២កន្លែងទំហំ ៧,៥០ ម គុណ ២៥ម និង ៩ម គុណ ២០ម ផ្ទះនៅឃុំប្រាំវិត ខេត្តស្វាយរៀង ដែលមាន បណ្ណសំគាល់សិទ្ធិលេខ សរ ០០១៤៥០ ចុះថ្ងៃទី ១៨.០២.២០០០ ត្រូវបែងចែកជាពីរចំណែកស្មើគ្នា ក្រោយពីការទូទាត់បំណុល អោយឈ្មោះ ឡុង សុធី ទេព្យា សុខារម្មណ៍ និង ធនាគារកាណាឌីយ៉ា រួចហើយ ។

៥-បង្គាប់អោយឈ្មោះ លី ធារី និង ទេព្យា ស៊ីសុផល រួមគ្នាបង់ពន្ធសមមាត្រ ១ភាគរយ លើទឹកប្រាក់ជំពាក់ ការប្រាក់ និង ជំងឺចិត្ត ដែលត្រូវសង ទៅអោយឈ្មោះ ឡុង សុធី - ទេព្យា សុខារម្មណ៍ និង ធនាគារកាណាឌីយ៉ា ។

៦-សាលដីការនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូភាគី តតិយជន ឈ្មោះ ឡុង សុធី មេធាវីការពារអោយឈ្មោះ ទេព្យា ស៊ីសុផល ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខ របស់លោក ពិត បូរ៉ាវុធ ចុះថ្ងៃទី ០៤.១០.២០០១ ជាមេធាវី របស់ឈ្មោះ ទេព្យា ស៊ីសុផល និង បណ្តឹងសាទុក្ខ របស់ឈ្មោះ ទេព្យា ស៊ីសុផល ចុះថ្ងៃទី ២២.១០.២០០១ ស្ថិតនៅក្នុងកំណត់ច្បាប់ ។

បានឃើញសារណា ចុះថ្ងៃទី ០២.០១.២០០២ របស់លោក ចាន់សុខយ៉ាង មេធាវីរបស់ឈ្មោះ ទេព្យា ស៊ីសុផល ។

បានឃើញសារណាតបចុះថ្ងៃទី ១៧.០១.២០០២ របស់លោក ផាត់ ពៅស៊ាង មេធាវីរបស់ឈ្មោះ ឡុង សុធី ។

បានឃើញសារណាតប ចុះថ្ងៃទី ០៧.៣.២០០២ របស់ឈ្មោះ លី ធារី ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា ៖

-បណ្តឹងសាទុក្ខលេខ ៣៤៨ ចុះថ្ងៃទី ០៤.១០.២០០១ របស់លោក ពិត បូរ៉ាវុធ ជាមេធាវី និង បណ្តឹងសាទុក្ខលេខ ៣៧៥ ចុះថ្ងៃទី ២២.១០.២០០១ របស់លោក ទេព្យាស៊ីសុផល ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យ ពិចារណា ។

-សាលដីការដ្ឋប្បវេណីលេខ ១៣១ "ឃ" ចុះថ្ងៃទី ២៣.៨.២០០១ របស់

សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់។ អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ទៀ ស៊ីសុផល ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា ។ :

-ខ្លួនមិនទទួលស្គាល់ បំណុល ៥ម៉ឺនដុល្លារនេះទេ ព្រោះខ្លួនមិនបានខ្ចី និង មិនបានដឹង ។

បានស្តាប់ចម្លើយរបស់ឈ្មោះ លី ធារី ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

-ដំបូងគឺលែងគ្នាលេងៗ ដើម្បីបំពេញសំណុំបែបបទ អោយប្តី និង កូន ចេញទៅបរទេស តែដល់ពេលទៅមិនបានស្រាប់តែលែងគ្នាមែនទែន ។ ចំពោះលុយ ៥ម៉ឺនដុល្លារនេះ គាត់មិនដឹងទេ ព្រោះខ្លួនជាអ្នក កាន់ការរកស៊ីនេះតែម្នាក់ឯង។

បានស្តាប់ចម្លើយរបស់ឈ្មោះ ឡុង សុធី ជាតតីយជន នៅពេលជំនុំជំរះឆ្លើយ ថា :

-សុំអោយតុលាការសំរេចអោយអ្នកទាំងពីរសងខ្លួនសិន ទើបសងអ្នកដទៃជាក្រោយ និង សុំអោយអ្នកទាំងពីរសងលុយខ្លួនវិញ ព្រោះពេលខ្ចី ឈ្មោះទៀស៊ីសុផល ក៏មកផ្ទះខ្លួនដែរ ហើយក្នុងការខ្ចីនេះ គឺខ្ចីច្រើនដង ទើបធ្វើកិច្ចសន្យាសរុប ដែលមាន ទឹកប្រាក់ចំនួន ៥ម៉ឺនដុល្លា និង បានសងវិញ ៧.000ដុល្លា ។

មេធាវីរបស់ ចុងចម្លើយធ្វើសេចក្តីសន្និដ្ឋានថា :

-ការបែងចែកទ្រព្យសម្បត្តិ ភាគីម្ខាងៗ សុទ្ធតែរកវិធីយ៉ាងណាឲ្យ បានទ្រព្យសម្បត្តិច្រើន មកខាងខ្លួន ហេតុដូច្នេះហើយ ទើបមានតតីយជន ដែលត្រូវជាក្មួយ ថ្លៃរបស់ឈ្មោះ លី ធារី មកប្តឹងទាមទារ ហើយសាក្សីជាបងបង្កើត របស់លី ធារី ឯម្ចាស់ បំណុល ត្រូវជាកូនរបស់ បង លី ធារី ។ ក្នុងកំណត់ហេតុផ្សះផ្សាសំរុះសំរួល របស់តុលាការក្រុងភ្នំពេញ ឈ្មោះ លីធារី បានឆ្លើយថា គ្មានជំពាក់ប្រាក់ អ្នកណាទេ គឺជំពាក់តែ ធនាគារ និង ឈ្មោះ លុ ខារម្មណី ប៉ុណ្ណោះ ក្រោយប្តឹងទាស់ហើយ ទើបចេញតតីយជន ។ ឈ្មោះ លី ធារី ក៏បានឆ្លើយនាពេលសវនាការនេះដែរថា ក្នុងការខ្ចីនេះ ឈ្មោះទៀស៊ីសុផល ក៏មិនបានដឹងដែរ ។

មេធាវីរបស់តតីយជន ធ្វើសេចក្តីសន្និដ្ឋាន ថា :

-ការលែងលះលើកទី១ លី ធារី បានឆ្លើយថា លែងគ្នាលេងៗ ដើម្បី បំពេញបែបបទទៅសហរដ្ឋអាមេរិក កូនក្តីខ្ញុំមិនបានដឹង ក្នុងការលែងលះគ្នានេះទេ ដល់ លែងគ្នាមែនទែន ទើបកូនក្តីខ្ញុំដឹង ដូច្នេះទើបកូនក្តីខ្ញុំប្តឹងទាមទារ ។ ចំពោះកិច្ច

សន្យាដែលទុកជាមោឃៈ ទាល់តែកិច្ចសន្យាខ្ចី រវាងប្ដីប្រពន្ធ មិនបានហាមឃាត់ ការខ្ចីលុយរវាងក្មួយ និង មីង ទេ ។ សុំតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់ សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ ចម្លើយរបស់ គូភាគី និង តតិយជន

សេចក្ដីសន្និដ្ឋានការពារ របស់មេធាវី ចុងចម្លើយ និង មេធាវី តតិយជន

- ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៣៥៨ ចុះថ្ងៃទី ៥.១០.២០០១ របស់លោក ឈិន បូរ៉ាវុធ ជាមេធាវី និង បណ្ដឹងសាទុក្ខលេខ ៣៧៥ ចុះថ្ងៃទី ២២.១០.២០០១ របស់លោក ទេព្យ ស៊ីសុផល ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៥ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្ដី ។

យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោម សំរេចអោយលោក ទេព្យ ស៊ីសុផល សងបំណុលទៅលោក ឡុង សុធី ដែលមានទឹកប្រាក់ចំនួន ៥០.០០០ដុល្លារអាមេរិកនោះ ជាការភ័ន្ដច្រឡំ ដោយសំអាងថា លិខិតខ្ចីប្រាក់ ចុះថ្ងៃទី ០៧.៥.៩៨ នេះ លោក ទេព្យ ស៊ីសុផល មិនបានដឹង ហើយក៏មិនដែលចូលរួមក្នុងការខ្ចីប្រាក់ពីលោក ឡុង សុធី និង ប្រពន្ធឈ្មោះ លៀង សុនីត្ថា ទេ គឺធ្វើចេញពីអ្នកស្រី លី ធារី តែម្នាក់ឯង ដោយពុំមានការព្រមព្រៀងពីលោកជាប្ដី ឡើយ ដែលជាការផ្ទុយ ពីមាត្រា៣៥ វាក្យខណ្ឌទី២ និង មាត្រា ៣៧ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

យល់ឃើញថា សាលាឧទ្ធរណ៍ គប្បីពិចារណាឡើងវិញ អំពីសំណងទៅធនាគារកាណាឌីយ៉ា ពីព្រោះធនាគារនេះ មិនបានប្ដឹងទារបំណុលនេះ នៅតុលាការក្រុង ឬ សុំចូលជាតតិយជន នៅសាលាឧទ្ធរណ៍ ទេ ។

យល់ឃើញថា អ្នកស្រី លី ធារី ក៏ទទួលស្គាល់ថា អ្នកស្រីពិតជាបានខ្ចីប្រាក់ពីឈ្មោះ លៀង សុនីត្ថា ប្ដីឈ្មោះ ឡុង សុធី នៅថ្ងៃទី ០៧.៥.៩៨ តែម្នាក់ឯង ប្រាកដមែន ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៣១ឈ ចុះថ្ងៃទី ២៣.៨.២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទំរង់ច្បាប់ ប៉ុន្តែគតិច្បាប់ ខុសខ្លះ ត្រូវខ្លះ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដី ចំពោះមុខ គូភាគី និង តតិយជន ព្រមទាំងមេធាវី ចុងចម្លើយ និង មេធាវី តតិយជន

១-ទទួលបណ្ដឹងសាទុក្ខលេខ ៣៤៨ ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០១ របស់លោក ឈិត ប៊ុនរ៉ាវុធ និង បណ្ដឹងសាទុក្ខលេខ ៣៧៥ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០១ របស់លោក ទេព្យា ស៊ីវុផល ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ១៣១ "ឃ" ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងចំនុច ទី៣ និង ទី៥ នៃ សាលដីកានេះ ត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣៤៤ ចុះថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ត្រង់ចំនុចទី៣ និង ទី៥ នៃសាលដីកាលេខ ១៣១ "ឃ" ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០១ របស់ សាលាឧទ្ធរណ៍ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដី ចំនួន ១៩.០០០៛ ដែលអ្នកស្រី លី ធារី បានបង់ជួល ទុកនៅតុលាការកំពូល រួចហើយ គឺ :

-ពន្ធចុះបញ្ជីក្ដី និង ពន្ធថ្លឹង ចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០២ ។